SOUTHERN CALIFORNIA EDISON®
Energy for What's Ahead®

# គម្រោងអត្រាតម្លៃសម្រាប់លំនៅដ្ឋាន

## ស្វែងយល់អំពីជម្រើសគម្រោងអត្រាតម្លៃថ្មីដែលមាន។

គេហដ្ឋានរបស់អ្នក ទំហំនៃគ្រួសាររបស់អ្នក កាលវិភាគរបស់អ្នក និងរបៀបរស់នៅរបស់អ្នកសុទ្ធតែដើរតួនាទីក្នុងការកំណត់តម្រូវការថាមពលអគ្គិសនីរបស់អ្នក។ គម្រោងអត្រារបស់យើងត្រូវបានបង្កើតឡើង ដូច្នេះអ្នកអាចរកឃើញភាពស័ក្តិសមត្រឹមត្រូវ និងទទួលបានអត្រាដ៏ល្អបំផុតសម្រាប់ការរស់នៅរបស់គ្រួសារអ្នក។

## ជ្រើសរើសពីកម្រិត ឬម៉ោងនៃការប្រើ។

មានអត្រាពីរប្រភេទដែលអ្នកអាចជ្រើសរើសគឺ កម្រិត ឬម៉ោងនៃការប្រើ(TOU)។

**អត្រាតាមកម្រិតផ្អែកទៅលើថាមពលប៉ុន្មានដែលអ្នកបានប្រើ។** នេះគឺជាគម្រោងទូទាត់វិក្កយបត្រតាមបែបប្រពៃណីជាងមុន។ អតិថិជនបង់ក្នុងអត្រាតែមួយគត់សម្រាប់បរិមាណ "គោល" នៃថាមពលជារៀងរាល់ខែ។ នៅពេលដែលចំណែកនោះប្រើអស់ អត្រានេះកើនឡើងដល់កម្រិតថ្លៃជាង។

**គម្រោងអត្រា TOU គឺផ្អែកទៅលើចំនួនប៉ុន្មាន និងពេលណាដែលអ្នកប្រើថាមពល។** គម្រោងមានអត្រាខុសៗគ្នាដោយផ្អែកលើពេលវេលានៃថ្ងៃ ថ្ងៃនៃសប្តាហ៍ និងរដូវ។ អត្រាតម្លៃអគ្គិសនីទាបជាងនៅពេលយប់ និងថ្ងៃចុងសប្តាហ៍ និងឡើងក្នុងអំឡុងពេលមមាញឹកនៅពេលកំពុងត្រូវការធនធានថាមពល។

| ជម្រើសគម្រោងអត្រាតម្លៃ | ព័ត៌មានលម្អិតអំពីគម្រោងអត្រាតម្លៃ | តើអ្នកណាអាចទទួលបានអត្ថប្រយោជន៍? |
|---|---|---|
| **កម្រិត** | មានតម្លៃពីរកម្រិត។ កម្រិតទី 1 គឺជាការបែងចែកតាមមូលដ្ឋានរបស់អ្នក។ កម្រិតទី 2 ចាប់ផ្តើមនៅពេលការប្រើថាមពលរបស់អ្នកលើសពីចំណែកនៃកម្រិតទី 1។ ថ្លៃប្រើប្រាស់ច្រើនក្រោមការគ្រប់គ្រងរបស់រដ្ឋក៏អាចអនុវត្តផងដែរ។ | • គ្រួសារដែលអាចរក្សាការប្រើប្រាស់ថាមពលឲ្យទាបពេញមួយខែ<br>• គ្រួសារដែលប្រើប្រាស់ថាមពលច្រើនក្នុងអំឡុងម៉ោងជិតល្ងាច និងម៉ោងជិតយប់ |
| **TOU-D-A**[1, 2] | មានម៉ោងពិសេសពេញមួយឆ្នាំចាប់ពីម៉ោង 10 យប់ដល់ម៉ោង 8 ព្រឹក។ អត្រាខ្ពស់បំផុតត្រូវបានទូទាត់ដោយឥណទានប្រចាំខែ។ | • អ្នកប្រើថាមពលកម្រិតទាប និងមធ្យម (តិចជាង 700 គីឡូវ៉ាត់ម៉ោង/ខែ។)<br>• អ្នករស់នៅផ្ទះល្វែងដែលមិនប្រើម៉ាស៊ីនត្រជាក់<br>• អតិថិជន NEM |
| **TOU-D-B**[1, 2] | មានម៉ោងពិសេសពេញមួយឆ្នាំចាប់ពីម៉ោង 10 យប់ដល់ម៉ោង 8 ព្រឹក។ ផ្តល់អត្រាទាបសម្រាប់ម៉ោងមមាញឹក ប៉ុន្តែគិតថ្លៃខ្ពស់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងគ្មានឥណទាន។ | • អតិថិជនប្រើថាមពលច្រើន (លើសពី 700 គីឡូវ៉ាត់ម៉ោង/ខែ។)<br>• គ្រួសារធំដែលមានកូន ឬមនុស្សចាស់<br>• គេហដ្ឋានដែលមានម៉ាស៊ីនត្រជាក់ ឬអាងហែលទឹក |
| **TOU-D-T**[2] | ការរួមបញ្ចូលគ្នារវាងតម្លៃអត្រា TOU និងតម្លៃអត្រាតាមកម្រិត។ ពីរកម្រិតនៃតម្លៃអត្រា TOU ត្រូវបានកំណត់ដោយការបែងចែកតាមមូលដ្ឋានរបស់អ្នក។ | • គ្រួសារដែលអាចរក្សាការប្រើប្រាស់ថាមពលឲ្យទាបពេញមួយខែ<br>• គ្រួសារដែលប្រើប្រាស់ថាមពលក្នុងពេលព្រឹកព្រលឹម ឬក្បាលល្ងាចក្នុងអំឡុងមួយសប្តាហ៍ |
| **TOU-D-4-9PM**[2] | មានម៉ោងពិសេសចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 4 រសៀលអំឡុងពេលរដូវរងារ (តុលា - ឧសភា)។ | • អតិថិជនដែលប្រើថាមពលមុនពេលជិតល្ងាច ឬពេលជិតយប់<br>• ផ្ទះចាប់ពីទំហំតូចរហូតដល់ទំហំមធ្យម |
| **TOU-D-5-8PM**[2] | មានម៉ោងពិសេសចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 5 រសៀលអំឡុងពេលរដូវរងារ (តុលា - ឧសភា)។ | • អតិថិជនដែលប្រើប្រាស់ថាមពលមុនម៉ោង 5 ល្ងាច។<br>• អ្នកដែលនៅផ្ទះក្នុងអំឡុងពេលថ្ងៃ<br>• ផ្ទះតូច |
| **TOU-EV-1**[2] | ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់បញ្ចូលថាមពលរថយន្តអគ្គិសនីដោយកុងទ័រវាស់មួយ។ | • អតិថិជនដែលមានរថយន្តអគ្គិសនី |

[1] ការចូលរួមក្នុងគម្រោងអត្រា TOU-D-A និង TOU-D-B មានកំណត់ ហើយសំណើសុំចុះឈ្មោះគឺផ្អែកលើគោលការណ៍អ្នកមកមុនបានមុន។
[2] តម្លៃសម្រាប់ម៉ោងធម្មតា និងសម្រាប់ម៉ោងពិសេសគឺតម្លៃក្នុងមួយគីឡូវ៉ាត់ម៉ោងទាបជាងតម្លៃសម្រាប់ម៉ោងមមាញឹក។

# គម្រោងអត្រាតម្លៃសម្រាប់លំនៅដ្ឋាន



## រក្សាទុកការបញ្ចុះតម្លៃរបស់អ្នក។

បើបច្ចុប្បន្នអ្នកកំពុងទទួលបានការបញ្ចុះតម្លៃតាមរយៈការចុះឈ្មោះនៅក្នុងកម្មវិធីអត្រាជម្រើសសម្រាប់ថាមពលនៃរដ្ឋកាលីហ្វ័រនីញ៉ា (CARE) ឬកម្មវិធីជំនួយអត្រាថាមពលអគ្គិសនីសម្រាប់គ្រួសារ (FERA) អ្នកនៅតែអាចជ្រើសរើសគម្រោងអត្រាដែលអ្នកពេញចិត្តបំផុតដោយមិនប៉ះពាល់ដល់ការបញ្ចុះតម្លៃរបស់អ្នក។

## ផ្លាស់ប្តូរគម្រោង ថ្ងៃនេះ។

ដើម្បីចុះឈ្មោះក្នុងគម្រោងអត្រាថ្មី ឬផ្លាស់ប្តូរទៅគម្រោងអត្រាខុសៗគ្នាសូមចូលទៅកាន់គេហទំព័រ **sce.com/rateanalyzer** ឬទូរស័ព្ទមកយើងខ្ញុំតាមរយៈលេខ **1-800-843-1309**។

# កម្មវិធី និងសេវាកម្មដែលមានប្រយោជន៍គឺអាចរកបាន។

យើងខ្ញុំប្តេជ្ញាចិត្តដើម្បីជួយអ្នកសន្សំថាមពល និងបន្ទាបតម្លៃវិក្កយបត្រថាមពលរបស់អ្នកតាមដែលអាចទៅបាន ហេតុនេះយើងខ្ញុំបានបង្កើតនូវកម្មវិធី និងសេវាកម្មដើម្បីជួយអ្នកឲ្យធ្វើបានបែបនោះ។

### ទីប្រឹក្សាថាមពល៖ 5 នាទីដើម្បីសន្សំសំចៃថាមពល

ការកាត់បន្ថយវិក្កយបត្រអគ្គិសនីប្រចាំខែរបស់អ្នកអាចកាន់តែងាយស្រួលជាងអ្នកគិត។ ជាមួយនឹងទីប្រឹក្សាថាមពលលើបណ្តាញរបស់យើងខ្ញុំ អ្នកនឹងទទួលបានវិធីសាមញ្ញ ហើយជាញឹកញយមានតម្លៃទាប ឬមិនគិតថ្លៃដើម្បីធ្វើឲ្យផ្ទះរបស់អ្នកមានប្រសិទ្ធភាពខាងថាមពលសមនឹងតម្លៃ និងបន្ទាបថ្លៃវិក្កយបត្រថាមពលរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ **sce.com/energysurvey**។

### វិធីឆ្លាតវៃក្នុងការស្វែងរកផលិតផលដ៏ល្អឥតខ្ចោះ។

ទទួលបានព័ត៌មានមានតម្លៃនៅតាមទីផ្សាររបស់យើងដែលអ្នកអាចស្វែងរកផលិតផលសម្រាប់បានពិន្ទុការសន្សំថាមពល ការពិនិត្យមើលឡើងវិញពីអ្នកលក់រាយ និងអ្នកជំនាញឈានមុខគេ ការក្រើនរំលឹកពីប្រាក់បង្វិលត្រលប់មកវិញ និងការធ្លាក់ថ្លៃ និងច្រើនថែមទៀត។ វាជាវិធីដ៏ឆ្លាតវៃបំផុតក្នុងការស្វែងរកផលិតផលដ៏ល្អឥតខ្ចោះរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ **marketplace.sce.com**។

### ទទួលបានជំនួយជាមួយសម្ភារបរិក្ខារវេជ្ជសាស្រ្ត។

ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្នុងក្រុមគ្រួសារអ្នកប្រើប្រាស់សម្ភារបរិក្ខារវេជ្ជសាស្រ្តដែលដើរដោយអគ្គីសនីអ្នកអាចនឹងមានសិទ្ធិសម្រាប់កម្មវិធីគោលមូលដ្ឋានវេជ្ជសាស្រ្តយើងខ្ញុំ ដែលបង្កើនការរៀបចំលៃទុកជាគោលមូលដ្ឋានរបស់អ្នកចំនួន 16.5 គីឡូវ៉ាត់ម៉ោងក្នុងមួយថ្ងៃ។ សម្រាប់ព័ត៌មានបន្ថែម សូមហៅទូរស័ព្ទទៅកាន់លេខ 1-800-447-6620 ឬចូលមើលគេហទំព័រ **sce.com/medicalbaseline**។

**Multicultural services**

| | |
|---|---|
| Cambodian / ខ្មែរ | 1-800-843-1309 |
| Chinese / 中文 | 1-800-843-8343 |
| Korean / 한국어 | 1-800-628-3061 |
| Vietnamese / Tiếng Việt | 1-800-327-3031 |
| Spanish / Español | 1-800-441-2233 |

## ឧបករណ៍លើបណ្តាញនៅឯគណនីរបស់ខ្ញុំ។

យើងបានបង្កើតក្រុមឧបករណ៍ដែលផ្តល់អំណាចឲ្យអ្នកតាមដានការប្រើប្រាស់ថាមពលរបស់អ្នក និងគ្រប់គ្រងលើតម្លៃចំណាយបានកាន់តែប្រសើរឡើង។ វាទាំងអស់ចាប់ផ្តើមជាមួយនឹងគណនីរបស់ខ្ញុំ ដែលអ្នកអាចត្រួតពិនិត្យតាមដានការប្រើប្រាស់របស់អ្នក និងភ្ជាប់ទៅកម្មវិធីដទៃផ្សេងទៀតរបស់យើងដូចជាកម្មវិធីជំនួយថវិកា និងការចេញវិក្កយបត្រដោយគ្មានក្រដាស។ សូមចុះឈ្មោះសម្រាប់ គណនីរបស់ខ្ញុំតាមអាសយដ្ឋាន **sce.com/myaccount**។

### ស្ថិតនៅមិនហួសខ្ទង់ចំណាយថវិកា និងគ្រប់គ្រងបាន

កម្មវិធីជំនួយថវិកា គឺជាឧបករណ៍ងាយស្រួលប្រើប្រាស់ដើម្បីតាមដានតម្លៃចំណាយលើថាមពលរបស់អ្នកនៅក្នុងពេលជាក់ស្តែងដ៏ខ្លីខាងមុខ ហើយផ្ញើជូនអ្នកនូវការរំលឹក តាមរយៈអ៊ីមែល ទូរស័ព្ទ ឬសារអក្សរដើម្បីឲ្យអ្នកដឹងថាតើអ្នកយ៉ាងម៉េចហើយ។ បង្ការការភ្ញាក់ផ្អើលដោយសារវិក្កយបត្រមានតម្លៃខ្ពស់ណាមួយដោយធ្វើការផ្លាស់ប្តូរមុនពេលអ្នកទទួលបានវិក្កយបត្របន្ទាប់របស់អ្នក។ គ្រាន់តែចូល ទៅក្នុងគណនីរបស់ខ្ញុំប៉ុណ្ណោះដើម្បីចាប់ផ្តើម។

### វិធីដ៏ឆ្លាតវៃក្នុងការបង់ប្រាក់។

រក្សាផ្ទះរបស់អ្នកឲ្យគ្មានភាពរាយប៉ាយជាមួយនឹងការចេញវិក្កយបត្រដោយគ្មានក្រដាស។ អ្នកនឹងមិនត្រូវការការបោះត្រាដើម្បីផ្ញើការបង់ប្រាក់របស់អ្នកនោះឡើយ ហើយអ្នកអាចមើលវិក្កយបត្ររបស់អ្នកបានយ៉ាងមានសុវត្ថិភាពនៅលើបណ្តាញបានពីឧបករណ៍ណាមួយ។ លើសពីនេះ ជាមួយនឹងការបង់ប្រាក់ដោយផ្ទាល់ វិក្កយបត្ររបស់អ្នកត្រូវបានបង់ទូទាត់ថ្លៃភ្លាមៗ។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីចុះឈ្មោះ សូមចូលទៅក្នុងគណនីរបស់ខ្ញុំ។

### សន្សំសំចៃថាមពល និងប្រាក់កាក់។

នៅក្រោមផ្ទាំងការប្រើប្រាស់ និងការគ្រប់គ្រងថាមពលនៅក្នុងគណនីរបស់ខ្ញុំ ចុចលើវិធីដើម្បីសន្សំសំចៃដើម្បីរកមើលសកម្មភាពសាមញ្ញដែលអ្នកអាចធ្វើបានដើម្បីសន្សំ ថាមពល និងបន្ទាបតម្លៃវិក្កយប័ត្ររបស់អ្នក។

នេះគឺគ្រាន់តែជាគន្លឹះមួយចំនួនតូចតែប៉ុណ្ណោះដើម្បីឲ្យអ្នកចាប់ផ្តើម៖

- ទុកឲ្យចានរបស់អ្នកស្ងួតតាមធម្មជាតិដោយប្រើប្រាស់មុខងារ "សម្ងួតដោយដាក់ឲ្យត្រូវខ្យល់"នៅលើម៉ាស៊ីនលាងចានរបស់អ្នក
- ផ្តល់ឲ្យម៉ាស៊ីនត្រជាក់អ្នកនូវការសម្រាក ហើយប្រើប្រាស់កង្ហារលើពិតាន និងកង្ហារដែលអាចចល័តផ្លាស់ទីបានដើម្បីធ្វើឲ្យខ្យល់ត្រជាក់ និងមានចរាចរណ៍រត់។
- សូមអាំងសាច់នៅខាងក្រៅអាគារ ឬប្រើប្រាស់ចង្ក្រានមីក្រូវ៉េវ ដើម្បីរក្សាផ្ទះរបស់អ្នកឲ្យកាន់តែត្រជាក់
- បោក និងលាងជម្រះសម្លៀកបំពាក់នៅក្នុងទឹកត្រជាក់
- ដកឆ្នាំងសាកសម្រាប់ទូរស័ព្ទ ថេប្លិត និងឧបករណ៍ផ្សេងដទៃទៀតនៅពេលដែលវាសាកថ្មពេញហើយ។
- បិទស្លាបព្រិល និងសន្ទះបង្ហាបង្អួចដើម្បីរក្សាកម្តៅនាពេលរសៀលកុំឲ្យចូលមកក្នុងបាន
- កំណត់ឧបករណ៍លៃតម្រូវសីតុណ្ហភាពនៅត្រឹម 78 អង្សានៅពេលនៅផ្ទះ និង "បិទ" នៅពេលអ្នកមិននៅ

©2018 Southern California Edison. រក្សាសិទ្ធិគ្រប់យ៉ាង។